
www.kidsofdestiny.org
Kids of Destiny®
Reaching the Next Generation

## 1.08 កំណើតអ៊ីសាក

តាំងពីយូរយារណាស់មកហើយ មានបុរសម្នាក់ឈ្មោះអ័ប្រាហាំ។ គាត់មានប្រពន្ធឈ្មោះសារ៉ា។ ពួកគេរស់នៅក្នុងស្រុកខារ៉ាន ជាកន្លែងដែលពួកគេបានធំឡើង។ ថ្ងៃមួយព្រះទ្រង់បានមានបន្ទូលទៅកាន់អ័ប្រាហាំថា ទ្រង់មានសារពិសេសណាស់ដើម្បីផ្តល់ឱ្យគាត់។ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា "ចូរចាកចេញពីស្រុកកំណើតរបស់ឯង ពីក្រុមគ្រួសារ និងផ្ទះឪពុករបស់ឯង ដើម្បីទៅទឹកដីដែលយើងនឹងបង្ហាញដល់ឯង។ យើងនឹងឱ្យពរ និងជាតិសាសន៍ដ៏ធំអស្ចារ្យមួយដល់ឯង។ ហើយគ្រប់ក្រុមគ្រួសារទាំងអស់នៅលើផែនដីនឹងត្រូវបានប្រទានពរដោយសារឯង ចូរឯងស្តាប់បង្គាប់ដល់យើង។

អ័ប្រាហាំនិងសារ៉ាបានប្រមូលទ្រព្យសម្បត្តិរបស់ពួកគេ ហើយធ្វើតាមអ្វីដែលព្រះទ្រង់បានបង្គាប់។ ពួកគេបានទៅដល់ទឹដីនៅស្រុកកាណាន។ លោកអ័ប្រាហាំមានអាយុ៧៥ឆ្នាំនៅពេលនោះ។ ព្រះទ្រង់បានប្រាប់ដល់ អ័ប្រាហាំថា ទ្រង់នឹងប្រគល់ទឹកដីនេះដល់កូនចៅរបស់គាត់។ ឥឡូវនេះ អ័ប្រាហាំជាអ្នកមានណាស់។ គាត់មានទ្រព្យសម្បត្តិជាច្រើន។ គាត់ក៏មានអ្នកបម្រើជាច្រើនដែរ។

នៅថ្ងៃមួយ អ័ប្រាហាំបានទូលទៅកាន់ព្រះថា៖ «តើទ្រព្យសម្បត្តិទាំងអស់នេះមានប្រយោជន៍ដល់ខ្ញុំយ៉ាងដូចម្តេចទៅ នៅពេលដែលខ្ញុំគ្មានកូនទុកវានៅពេលខ្ញុំស្លាប់ទៅ? តើត្រូវទុកទ្រព្យសម្បត្តិរបស់ខ្ញុំឲ្យអ្នកបំរើឬ? ព្រះទ្រង់បានប្រាប់គាត់ថា កុំឲ្យបារម្ភឡើយ៖ «មើលផ្កាយលើមេឃចុះ! អ័ប្រាហាំអើយ! តើឯងអាចរាប់ពួកវាអស់ទេ? នោះគឺជាចំនួនកូនចៅដែលឯងនឹងមានហើយ។ ឯងនឹងមានគ្រួសារដ៏ធំមួយ"។ អ័ប្រាហាំជឿលើព្រះអម្ចាស់ ព្រោះការនោះវាពិតជាសំខាន់ណាស់សម្រាប់គាត់។

ព្រះទ្រង់បានបន្តប្រាប់អ័ប្រាហាំ អំពីគ្រួសារដែលគាត់នឹងមាន។ ព្រះទ្រង់បានប្រាប់អ័ប្រាហាំថា នឹងមានបញ្ហាជាច្រើន។ បណ្តាជន នឹងមិនស្តាប់បង្គាប់ព្រះអម្ចាស់ទេ។ ប៉ុន្តែ ព្រះនៅតែប្រទានទឹកដីកាណានឲ្យដល់ពួកគេ។ សារ៉ាមិនជឿដូចអ័ប្រាហាំអំពីការមានកូនទេ។ អ័ប្រាហាំក៏មានការសង្ស័យខ្លះដែរ។ គាត់មានអាយុ១០០ឆ្នាំហើយ។ សារ៉ាមានអាយុ៩០ឆ្នាំ។

នៅថ្ងៃមួយ មានមនុស្សបីនាក់បានទៅលេងអ័ប្រាហាំ។ គាត់បានអញ្ជើញពួកគេចូលក្នុងតង់របស់គាត់។ សារ៉ាក៏បានធ្វើនំប៉័ងខ្លះៗ។ ពួកគេក៏មានសាច់អាំងទឹកដោះគោជូរនិងទឹកដោះគោផងដែរ។ តើនេះជាពិធីអ្វីទៅ? បុរសម្នាក់បាននិយាយថា "ឆ្នាំក្រោយអ្នកនិងប្រពន្ធរបស់អ្នកនឹងមានកូនប្រុសម្នាក់! "សារ៉ាបានសើច។ តើស្ត្រីចំណាស់ដូចខ្ញុំអាចមានកូនយ៉ាងម៉េចទៅ? ជាពិសេស ប្តីរបស់ខ្ញុំក៏ចាស់ណាស់ដែរ។ ព្រះអម្ចាស់បានឮសារ៉ាសើច។ ហេតុអ្វីបានជាអ្នកសើចដូច្នេះ? ទ្រង់បានសួរ។ "តើមានអ្វីដែលពិបាកសំរាប់ព្រះអម្ចាស់ទេ?

ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «យើងបានរើសអ័ប្រាហាំឲ្យទទួលពរ។ កូនៗរបស់ឯងនឹងក្លាយជាជាតិសាសន៍មួយយ៉ាងធំដ៏អស្ចារ្យនិងខ្លាំងក្លា។ ជាតិសាសន៍ទាំងអស់នៅលើផែនដីនឹងទទួលពរតាមរយៈឯង។ យើងបានជ្រើសរើសឯងដើម្បីឲ្យកូនប្រុស និងក្រុមគ្រួសាររបស់ឯងគោរពតាមមាគ៌ារបស់ព្រះអម្ចាស់ដោយប្រព្រឹត្តដ៏ត្រឹមត្រូវ។ យើងនឹងធ្វើអ្វីៗទាំងអស់ដែលយើងបានសន្យាចំពោះអ័ប្រាហាំ"។ ព្រះអម្ចាស់ទ្រង់បានរក្សាការសន្យារបស់ទ្រង់ចំពោះអ័ប្រាហាំ។

ប្រហែលជាមួយឆ្នាំក្រោយមក សារ៉ាបានបង្កើតកូនប្រុសមួយឲ្យអ័ប្រាហាំ ពេលគាត់មានអាយុចាស់ដូចព្រះបានប្រាប់មែន។ អ័ប្រាហាំដាក់ឈ្មោះកូនប្រុសរបស់ពួកគេថា អ៊ីសាក ដែលមានន័យថា អ្នកចំអក។ សារ៉ារីករាយណាស់!នាងនិយាយថា "ព្រះអម្ចាស់ទ្រង់បានធ្វើឲ្យខ្ញុំសើច! តើអ្នកណានឹងដឹងថា ខ្ញុំនឹងមានកូន? ខ្ញុំបានផ្តល់កូនប្រុស១ដល់អ័ប្រាហាំនៅអាយុចាស់ជរា! »។
ព្រះទ្រង់អាចធ្វើគ្រប់ការទាំងអស់បាន។
(លោកុប្បត្តិ ១២, ១៥, ១៨ និង ២១)

## 1.08 កំណើតអ៊ីសាក់ - សេចក្តីណែនាំរបស់គ្រូបង្រៀន

**កំណត់សម្គាល់**:

១) ព្រះទ្រង់បានស្នើសុំឱ្យអ័ប្រាហាំនិងភរិយារបស់គាត់ឈ្មោះសារ៉ា ចាកចេញពីផ្ទះរបស់ពួកគេ ហើយផ្លាស់ទៅទឹកដីដែលហៅថា ស្រុកកាណាន ។

២) ព្រះទ្រង់បានប្រាប់អ័ប្រាហាំថា គាត់នឹងមានកូនចៅជាច្រើន ដូចជាផ្កាយនៅលើមេឃ ។

៣) បុរស៣នាក់បានទៅលេងអ័ប្រាហាំ ។ បុរសម្នាក់ក្នុងចំណោមបុរសទាំងនោះបានប្រាប់អ័ប្រាហាំថា នៅពេលនេះ ឆ្នាំក្រោយ អ័ប្រាហាំនិងប្រពន្ធរបស់គាត់នឹងមានកូនប្រុសម្នាក់ ។

៤) សារ៉ាមិនជឿបុរសទាំនោះទេ ។ នាងបានសើច ។ នាងគិតថានាង និងអ័ប្រាហាំមានអាយុចាស់ណាស់ទៅហើយក្នុងការមានកូន ។

៥) ព្រះបានរក្សាការសន្យារបស់ទ្រង់ ។ នៅឆ្នាំបន្ទាប់អ័ប្រាហាំនិងសារ៉ាក៏មានកូនប្រុសម្នាក់ ។ អ័ប្រាហាំដាក់ឈ្មោះថាអ៊ីសាក់ ។

**សំណួរ:**

១) ហេតុអ្វីអ័ប្រាហាំ និងសារ៉ាចាកចេញពីផ្ទះ?

២) តើព្រះបានប្រាប់អ័ប្រាហាំថាគាត់នឹងមានកូនចៅប៉ុន្មាននាក់?

៣) តើភ្ញៀវម្នាក់ក្នុងចំណោមភ្ញៀវ ៣នាក់ បានប្រាប់អ័ប្រាហាំអំពីអ្វីខ្លះ?

៤) ហេតុអ្វីបានជាសារ៉ាសើច?

៥) តើព្រះបានធ្វើតាមការសន្យារបស់ទ្រង់ទេ?

៦) តើទារកនោះមានឈ្មោះអ្វី?

**ចម្លើយ:**

១) អ័ប្រាហាំ និងសារ៉ាបានចាកចេញពីផ្ទះរបស់ពួកគេ ពីព្រោះព្រះបានបង្គាប់ដល់ពួកគេ។

២) ព្រះទ្រង់បានប្រាប់អ័ប្រាហាំថាកូនចៅរបស់គាត់នឹងមានចំនួនដូចជាផ្កាយនៅលើមេឃ។

៣) ភ្ញៀវម្នាក់បានប្រាប់អ័ប្រាហាំថា គាត់និងសារ៉ានឹងមានកូនប្រុសម្នាក់នៅឆ្នាំក្រោយ។

៤) សារ៉ាសើចព្រោះនាងគិតថា នាងនិងអ័ប្រាហាំចាស់ពេកមិនអាចមានកូនបានទេ។

៥) ព្រះទ្រង់បានរក្សាការសន្យារបស់ទ្រង់។

៦) ទារកនោះមានឈ្មោះថា អ៊ីសាក។



www.kidsofdestiny.org